II- រាជរដ្ឋាភិបាល

អនុក្រឹត្យ

អនុក្រឹត្យលេខ ១៩ អនក្រ.បក

ស្តីពីការលុបនាទីឡូត៍នេសាទ

និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ

ខេត្តបន្ទាយមានជ័យ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

មាត្រា ១.

វិបានកែសំរួលប្រកាសលេខ ០០៨០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និង កន្លែងនេសាទបំរុងទុកនៅទឹកសាប ក្នុងខេត្តបន្ទាយមានជ័យ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទលេខ៣ និងលេខ៤ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅដោយរក្សាទុកអន្លង់ត្រីមេពូជដូចខាងក្រោម :
  - ឡូត៍នេសាទលេខ ៣ រក្សាទុកអន្លង់ត្រីមេពូជមួយកន្លែងត្រង់ចំនុចវត្តតាសល់ ក្នុងឃុំគោកបាឡាំង ដែលមានចំងាយសងខាងវត្តមួយគីឡូម៉ែត្រផ្នែកខាងលើ និងមួយគីឡូម៉ែត្រផ្នែកខាងក្រោម ដែលមានផ្ទៃក្រឡាសរុប ៩ ហិកតា ។
  - ឡូត៍នេសាទលេខ ៤ រក្សាទុកអន្លង់ត្រីមេពូជនៅត្រង់ចំនុចវត្តភ្លៀត ក្នុងភូមិភ្លៀត និងអន្លង់វត្តកោះ ។ អន្លង់ទាំងពីរនេះត្រូវរក្សាការពារ ចាប់ពីមាត់អន្លង់តាមបណ្តោយដងស្ទឹងទៅខាងលើ ២០០ម និងពីមាត់អន្លង់ទៅខាងក្រោម ២០០ម ដែលមានផ្ទៃក្រឡាសរុប ៤ ហិកតា ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តបន្ទាយមានជ័យ និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តបន្ទាយមានជ័យ ដែលត្រូវលុប និងកាត់បន្ថយ

ឯកតា (ហិកតា)

ប្រភេទ និង លេខឡូត៍	ផ្ទៃឡូត៍ នេសាទ	ផ្ទៃឡូត៍ កាត់ចេញ	ផ្ទៃឡូត៍ នៅសល់	ផ្ទៃឡូត៍កាត់ គិតជាភាគរយ	ផ្សេងៗ
បឹងព្រែក					
១	១២.៩១៦	១១.៧៣៨	១.១៧៨	៩០.៨៨	
២	៥.៣៤៣	១២៣	៥.២២០	២.៣០	
៣	៧.៤៧០	៧.៤៦១	៩	៩៩.៨៧	លុបចេញ រក្សាទុក ៩ ហ.ត
៤	៧.០២៧	៧.០២៣	៤	៩៩.៩៤	លុបចេញ រក្សាទុក ៤ ហ.ត
សរុប ៤	៣២.៧៥៦	២៦.៣៤៥	៦.៤១១	៨០.៤២	

មាត្រា ២.-

ដែននេសាទដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

មាត្រា ៣ .-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

មាត្រា ៤ .-

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

អនុក្រឹត្យលេខ ២០ អនក្រ.បក

ស្តីពី

ការលុបនាទីឡូត៍នេសាទ និងរក្សាទុកដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តក្រចេះ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា